រឿង

# ចិន្ដាពូកែចង់ដឹងចង់យល់







ចិន្ដាចង់ក្លាយជាវេជ្ជបណ្ឌិត។ នាងទៅសាលារៀនជា
រៀងរាល់ថ្ងៃទោះជាភ្លៀង ឬថ្ងៃក្ដៅយ៉ាងណាក៏ដោយ។

ចិន្តាចូលចិត្តញ៉ាំត្រី ពីព្រោះម្តាយរបស់នាងបាន
ប្រាប់នាងថា ញ៉ាំត្រីធ្វើឱ្យនាងរឹងមាំ និងមានប្រាជ្ញា
ឈ្លាសវៃ។ នាងជាសិស្សពូកែនៅក្នុងថ្នាក់រៀន។





សូម្បីតែនៅផ្ទះ នាងតែងតែស្វែងយល់ និងសួរសំនួរ
ដែលនាងឆ្ងល់។ ដូចជាថ្ងៃនេះនាងបានឃើញឪពុក
របស់នាងកំពុងបុកត្រីល្អិតធ្វើជាម្សៅត្រី។



ចិន្តាសួរ៖ ពុក! តើពុកកំពុងធ្វើអ្វីហ្នឹង?
ឪពុកឆ្លើយ៖ ពុកកំពុងបុកត្រីល្អិតដែលលីងរួចហ្នឹងធ្វើជាម្សៅត្រី ដើម្បីយើងអាចមានម្សៅត្រីល្អិតញ៉ាំនៅរដូវប្រាំងជិតចូលមកដល់ហ្នឹងណាកូន!
ចិន្តាសួរ៖ អីចឹងតើអាអូនចាន់នីអាចញ៉ាំម្សៅត្រីហ្នឹងបានដែរឬទេពុក?
ឪពុកឆ្លើយ៖ ពិតណាស់! នៅពេលដែលគេអាយុបានប្រាំមួយខែ ម្សៅត្រីហ្នឹងល្អណាស់សម្រាប់ឱ្យគេញ៉ាំ។
អូហ៎ូ! មើលទៅចិន្តា
នាងដូចជាសប្បាយ
ចិត្តខ្លាំងណាស់!





ចាន់នីជាប្អូនប្រុសរបស់ចិន្តា។ គេមានអាយុជិតប្រាំមួយខែហើយ។ សព្វថ្ងៃគេបៅតែទឹកដោះម្តាយប៉ុណ្ណោះ។ ចិន្តាតែងតែគិតដល់ប្អូនប្រុសរបស់នាង ពីព្រោះនាងចង់ក្លាយជាវេជ្ជបណ្ឌិតជំនាញពិសេសម្នាក់គឺពេទ្យកុមារ។ នាងបានរៀនសូត្រពីមុខងាររបស់ពេទ្យកុមារនៅឯសាលារៀន។



ព្រឹកថ្ងៃបន្ទាប់ ចិន្តាបានភ្ញាក់ពីគេងតាំងពីព្រលឹម ទោះបីវាជាថ្ងៃ
ឈប់សម្រាកពីសាលាក៏ដោយ។
ចិន្តានិយាយ៖ ម៉ែៗ! តោះយើងទៅរកត្រីល្អិតនៅតាមវាលស្រែ
ណាម៉ែ ព្រោះកូនស្គាល់កន្លែងដែលសំបូរត្រីច្រើន។





ក្រោយត្រឡប់មកពីរកត្រីវិញ
ចិន្តានិយាយ៖ ពុក! ការរកត្រីងាយស្រួលអីចឹងតើ។
មើលនែ៎ គ្រាន់តែមួយព្រឹកសោះយើងរកត្រីបានយ៉ាង
ច្រើន។ អីចឹងតើកូនអាចជួយពុកបុកត្រីលីងបានទេថ្ងៃ
នេះដើម្បីឱ្យយើងអាចមានម្សៅត្រីច្រើនសម្រាប់អាអូន
ចាន់នី ?កូនចង់ឱ្យអាអូនចាន់នី
លូតលាស់ប្រកបដោយ
សុខភាពល្អ មានភាព
សប្បាយរីករាយ និង
មានប្រាជ្ញាឈ្លាសវៃ។
ឪពុកឆ្លើយ៖ បាទ
មិនអីទេកូន!









ក្រោយមកក្នុងឆ្នាំនោះដដែល ចិន្តាបានជួយម្តាយរបស់នាងចម្អិនសម្លប្រហើរ។ នាងបានជួយបេះបន្លែដែលឪពុករបស់នាងបានដាំនៅជុំវិញផ្ទះ ព្រមទាំងបានដាក់ម្សៅត្រីល្អិតដែលនាង និងឪពុករបស់នាងបានធ្វើជាមួយគ្នា។
ចិន្តាចូលចិត្តបញ្ចុកម្សៅត្រីល្អិតដល់ប្អូនរបស់នាងដោយកិនលាយជាមួយល្ពៅចំហុយ ឬការ៉ុត ឬដំឡូងស្ងោរ។

ញ៉ាំៗ! ញ៉ាំទៅអាអូន! ត្រីនឹងជួយឱ្យអាអូនឯងលូតលាស់ មានសុខភាពល្អមានកម្លាំងរឹងមាំ និងឈ្លាសវៃទៀតផង!

ម្ដាយរបស់ចិន្ដាបាននិយាយទៅកាន់នាងថា៖ ពុកម៉ែមានមោទនភាពចំពោះកូន និងចាន់នីខ្លាំងណាស់។ ពុកម៉ែចង់ផ្ដល់អ្វីៗដែលល្អបំផុតសម្រាប់កូនៗ។





# លូតលាស់
# ទាំងអស់គ្នា

ការបដិសេធ៖

ឈុតផ្សព្វផ្សាយតាមរយៈទូរទស្សន៍នេះ ត្រូវបានរៀបចំឡើងក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាម រយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ( USAID ) ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការលេខ No. AID-442-A-14-00006 ។ ខ្លឹមសារនៃឈុតផ្សព្វផ្សាយនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍនអន្តរជាតិ ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកនោះឡើយ។